**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៧១៧៥.....អពដ

GENERAL DEPARTMENT OF TAXATION

L202104130109 | TD2799

ថ្ងៃសុក្រ ៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់ជ្រាបថា យោងតាមសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនអ្នកជាប់ពន្ធនិងភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ដែលនៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ធ្វើការបំពេញលិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញ (Online) ដែលអគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍ និងបានដាក់ឱ្យប្រើប្រាស់នាពេលកន្លងមក។ ក្នុងន័យនេះ អ្នកជាប់ពន្ធទាំងអស់អាចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញ ដោយអនុវត្តតាមជម្រើសមធ្យោបាយដូចខាងក្រោម÷

១. សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំអាចបំពេញនិងដាក់លិខិតប្រកាសប្រចាំខែតាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) និងធ្វើការទូទាត់ប្រាក់ពន្ធតាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) ដោយចូលទៅកាន់អាសយដ្ឋាន https://www.tax.gov.kh/km/e-service។ សម្រាប់អ្នកជាប់ពន្ធតូចអាចបំពេញនិងដាក់លិខិតប្រកាសប្រចាំខែតាមរយៈកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) ដែលអាចចូលទៅទាញយកបានតាម App Store ( សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ iOS) ឬ Play Store ( សម្រាប់អ្នកប្រើប្រាស់ទូរស័ព្ទដៃតាមប្រព័ន្ធ Android) និងអាចធ្វើការទូទាត់ប្រាក់ពន្ធជាស្វ័យប្រវត្តិ។ សម្រាប់នីតិវិធីលម្អិតសូមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំលេខ ០០៣ សហវ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធស្រាប់។

២. ក្នុងករណីអ្នកជាប់ពន្ធនៅមិនទាន់មានលទ្ធភាពប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) ឬកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) អ្នកជាប់ពន្ធអាចបំពេញលិខិតប្រកាសពន្ធប្រចាំខែដោយដៃ និងបង់ប្រាក់ពន្ធដោយប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) រួចស្កេនបញ្ជូនលិខិតប្រកាសនិងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធតាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិក (E-Document) ដោយចូលទៅកាន់អាសយដ្ឋាន https://www.tax.gov.kh/km/e-service។ សម្រាប់នីតិវិធីលម្អិតសូមអនុវត្តដូចខ្លឹមសារនៃសេចក្តីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធស្រាប់។

ដើម្បីជាការសម្រួលដល់ដំណើរការនៃការដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែ សម្រាប់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងប្រភេទអាជីវកម្មត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និង



អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L202104130109 | TD2799

ក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងអ្នកជាប់ពន្ធដែលមិនស្ថិតក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ កាលបរិច្ឆេទផុតកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែមីនា ដែលត្រូវធ្វើនៅក្នុងខែមេសានេះ នឹងត្រូវបានអនុញ្ញាតឱ្យពន្យាររហូតដល់ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១។ ដោយឡែក អ្នកជាប់ពន្ធដែលស្ថិតក្នុងប្រភេទអាជីវកម្មដែលត្រូវបានហាមឃាត់ក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ កាលបរិច្ឆេទផុតកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែមីនា ដែលត្រូវធ្វើនៅក្នុងខែមេសានេះ នឹងត្រូវបានអនុញ្ញាតឱ្យពន្យាររហូតដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១។

បន្ថែមពីនេះ ក្នុងគោលដៅគាំទ្រដល់ការប្រើប្រាស់និងផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំរួចរាល់នូវក្រុមការងារសេវាគាំទ្រ (e-Tax Service) ដើម្បីដោះស្រាយបញ្ហានានាក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសតាមអនឡាញ និងមជ្ឈមណ្ឌលCall Center 1277 ដើម្បីដោះស្រាយឬឆ្លើយតបនឹងចម្ងល់និងបញ្ហានានារបស់អ្នកជាប់ពន្ធ។ ដោយឡែក ក្នុងរយៈពេលនៃការបិទខ្ទប់ អគ្គនាយកដ្ឋានពន្ធដារសូមជំរុញនិងលើកទឹកចិត្តឱ្យភ្នាក់ងារសេវាកម្មពន្ធដារដែលជួបប្រទះបញ្ហាប្រឈមក្នុងការទទួលនិងបញ្ជូនឯកសារពីអ្នកជាប់ពន្ធជាអតិថិជនដើម្បីរៀបចំប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែគួរប្រើប្រាស់សារអេឡិចត្រូនិក (E-mail) ឬមធ្យោបាយអេឡិចត្រូនិកនានា ដើម្បីបញ្ជូននិងទទួលឯកសារជាទម្រង់ Soft Copy និងរៀបចំប្រកាសនិងបង់ប្រាក់ពន្ធតាមយន្តការខាងលើ។

សេចក្តីដូចបានជម្រាបខាងលើ សូមអ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

អគ្គនាយកដ្ឋានពន្ធដារ

Grant Thornton (Cambodia) Limited
Unofficial translation

**KINGDOM OF CAMBODIA**
**NATION RELIGION KING**
*****************

**MINISTRY OF ECONOMY AND FINANCE**
**GENERAL DEPARTMENT OF TAXATION**
No. 7175 GDT

Phnom Penh, 16 April 2021

# NOTIFICATION

The General Department of Taxation ("GDT") of the Ministry of Economy and Finance is honor to inform taxpayers, tax agents and public that pursuant to Decision no. 49 SSR dated 14 April 2021 on the lockdown of Phnom Penh Capital and Ta Khmav city of Kandal Province in order to curb with the spread of Covid-19, the GDT would like to inform all taxpayers and tax agents locating in lockdown area to file tax return and pay tax online which the GDT has developed and put into use previously. By this, all taxpayers can file monthly tax return and pay tax online by choosing below options: -

1. For medium and large taxpayers can file and submit monthly tax return via E-filing system and make tax payment though e-payment by visiting http://www.tax.gov.kh/km/e-service. For small taxpayers can file and submit monthly tax return via GDT Tax Prefilling App by downloading from App Store (for iOS users) or Play Store (for Android users) and can make automatic tax payment. For detail procedures, please follow the Instruction no. 003 MEF dated 27 February 2020 of the Ministry of Economy and Finance as attached with the appendix.

2. In case taxpayers cannot use the e-filing system or GDT Tax Prefilling App yet, taxpayers can complete tax return manually and make payment online with e-payment then scan and upload the tax returns and tax receipt through E-Document by visiting http://www.tax.gov.kh/km/e-service. For detail procedures please follow Instruction no. 7705 GDT dated 19 March 2020 of the GDT as attached with the appendix.

In order to facilitate the process of monthly tax submission and payment for taxpayers whose businesses are allowed to continue operation during the implementation of lockdown as stated in article 3 of Decision no. 49 SSR dated 14 April 2021 on the lockdown of Phnom Penh Capital and Ta Khmav city of Kandal Province in order to curb with the spread of Covid-19 and taxpayers who are not located in the lockdown area, the deadline of tax submission and payment for March which shall be filed this April shall be allowed to extend until 27 April 2021. However, for taxpayers whose businesses are prohibited in the lockdown area, the deadline for tax submission and payment for March which shall be filed this April shall be allowed to extend until 15 May 2021.

Additionally, in order to support the usage and facilitate taxpayers, the GDT has already prepared a support team (e-Tax Service) in order to solve any issues during the usage of e-filing and Call Cener 1277 in order to solve or answer any queries and issues of taxpayers. However, during the lockdown period, the GDT would like to encourage tax agents who face issues in receiving and delivering documents from client who are taxpayers in order to prepare monthly tax filing and payment should use E-mail or other electronic methods in order to send and receive documents in soft copy and prepare monthly tax filing and payment as per above mechanism.

As mentioned above, please taxpayers, tax agents and public be informed and jointly implement effectively.

THE GENERAL DEPARTMENT OF TAXATION